# រឿងទី១១៖ កូនពៅវង្វេង

**ខគម្ពីរ៖ លូកា១៥៖៣២**

យើងត្រូវតែសប្បាយរីករាយ ដ្បិតប្អូនរបស់ឯងដែលបានស្លាប់ទៅនោះ ឥឡូវនេះ រស់ឡើងវិញហើយ។ វាបានវង្វេងបាត់ តែឥឡូវនេះ យើងរកឃើញវិញហើយ»។

កាលពីយូរលង់មកហើយ នៅក្នុងភូមិមួយមានបុរសម្នាក់ និងកូនប្រុសពីរនាក់។
បុរសនោះស្រឡាញ់កូនប្រុសទាំងពីររបស់គាត់ខ្លាំងណាស់។
ក្នុងចំណោមកូនទាំងពីរ កូនច្បងជាកូនដែលស្តាប់បង្គាប់ឪពុក។
ប៉ុន្តែកូនប្រុសពៅជាកូនដែលចូលចិត្តតែការលេងសប្បាយ។
មានថ្ងៃមួយ កូនពៅបានគិតថាចង់ចាកចេញពីផ្ទះ ទៅរស់នៅដោយខ្លួនឯង។
គឺដោយសារតែគាត់គិតថា បើសិនជាចាកចេញពីផ្ទះ នោះគាត់អាចធ្វើអ្វីបានតាមចិត្ត។
កូនពៅបាននិយាយទៅកាន់ឪពុកថា៖ «លោកឪពុក! សូមចែកកេរមត៌កឱ្យកូនមក! កូនចង់ចាកចេញពីផ្ទះ ទៅរស់នៅដោយខ្លួនឯង!
ឪពុកពិបាកចិត្តដោយព្រោះកូនចាកចេញទៅ ប៉ុន្តែគាត់បានចែកកេរមត៌កឱ្យតាមអ្វីដែលគាត់សុំ។
កូនពៅបានទទួលកេរមត៌កហើយ ក៏បានចាកចេញទៅ។ គាត់បានធ្វើដំណើរទៅដល់ស្រុកមួយធំស្រស់ឆើតឆាយ គាត់បានហៅមិត្តភក្តិថ្មី
បរិភោគអាហារឆ្ងាញ់ៗ ផឹកស្រាទំពាំងបាយជូរថ្លៃៗ។
ហើយទិញត្បូង សំលៀកបំពាក់ថ្លៃៗប្រៀបនឹងស្តេច វាបានចាយវាយប្រាក់យ៉ាងខ្ជះខ្ជាយ។
ទីបំផុត កូនពៅក៏បានចាយវាយទ្រព្យសម្បត្តិដែលបានពីឪពុកអស់ទៅ។
នៅពេលដែលអស់ទ្រព្យសម្បត្តិ មិត្តភក្តិក៏បានចាកចេញពីគាត់។ កូនពៅធ្លាក់ខ្លួនតោកយ៉ាក និងឯកោ។
កូនពៅមិនអាចអត់ទ្រាំនឹងភាពស្រេកឃ្លានបាន ក៏ចូលទៅធ្វើជាអ្នកបម្រើនៅក្នុងផ្ទះមួយ។
កូនពៅពិបាក និងសោកសៅណាស់។ ពេលនោះ គាត់បាននឹកឃើញដល់ឪពុក។
គាត់ចង់ត្រឡប់ទៅកាន់ឪពុករបស់គាត់វិញ។
ដូច្នេះ កូនពៅក៏បានត្រឡប់ទៅស្រុកកំណើតវិញ។





នៅពេលដែលទៅកាន់តែជិតដល់ផ្ទះរបស់ឪពុកគាត់ គាត់បារម្ភ និងភ័យព្រួយ។
កូនពៅដើរបណ្ដើរ យំបណ្ដើរ ដើរឆ្ពោះសំដៅទៅផ្ទះឪពុក។
ប៉ុន្តែ ឪពុកបានឃើញកូនពៅពីចម្ងាយ។
ឪពុកតែងតែឈរនៅមុខទ្វារជារៀងរាល់ថ្ងៃ រង់ចាំរហូតកូនពៅត្រឡប់មកវិញ។
ពេលដែលឃើញកូនពៅភ្លាម ឪពុកបានស្ទុះទៅឱបកូន។
ឪពុកប្រាប់ទៅកាន់ពួកអ្នកបម្រើថា៖ «ចូរទៅយកសំលៀកបំពាក់ល្អៗបំផុត មកពាក់ឱ្យកូនខ្ញុំជាប្រញាប់ ហើយយកចិញ្ចៀន និងស្បែកជើង
មកពាក់ឱ្យផង។ ចូរយកកូនគោដែលយើងបានបំប៉នទុក មកកាប់ជប់លៀងឱ្យសប្បាយចុះ!»
ឪពុករីករាយណាស់ ហើយបានធ្វើពិធីជប់លៀងយ៉ាងធំ។
ចុងក្រោយ កូនពៅក៏បានយល់អំពីក្ដីស្រឡាញ់ដ៏ធំធេងរបស់ឪពុក។



**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. ហេតុអ្វីបានជាកូនពៅ ចង់ចាកចេញពីផ្ទះ?

------------------------------------------------------------

b. តើឪពុកបានធ្វើអ្វីជារៀងរាល់ថ្ងៃ បន្ទាប់ពីកូនពៅចាកចេញពីផ្ទះ?

------------------------------------------------------------

c.សូមអានលូកា ១៥៖១១-៣២។ តើឪពុកបានធ្វើអ្វីខ្លះនៅពេលដែលកូនប្រុសពៅត្រឡប់មកដល់ផ្ទះវិញ?

------------------------------------------------------------

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (លូកា១៥៖៣២)

**យើងត្រូវតែសប្បាយរីករាយ ដ្បិតប្អូនរបស់ឯងដែលបានស្លាប់ទៅនោះ ឥឡូវនេះ រស់ឡើងវិញហើយ។**

**សកម្មភាពទី២** សកម្មភាព២ សូមស្វែងរករូបអាថ៌កំបាំងចំនួន១០។

▶ សំបុត្រ, ផ្កាយ, បេះដូង, ទៀន, ត្បូង



**សកម្មភាព៣** សូមគិតអំពីខ្លឹមសារមេរៀនដែលបានរៀននេះថ្ងៃនេះ រួចផាត់ពណ៌រូបខាងក្រោម។



KIDS GOD WORSHIP
www.kidsworship.kr

Selah
Ministry of Christian Publishing

ឈ្មោះ: